ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែតុលា ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែតុលា ឆ្នាំ២០១៦នេះ ប្រជាកសិករបានខិតខំជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សាយ៉ាងសស្រាក់សស្រាំ។ គិតមកទល់ចុងខែតុលា ឆ្នាំ២០១៦នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាត្រូវបានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបានលើផ្ទៃដី២ ៥៩៧ ៤១២ហ.ត ស្មើនឹង ១០៤,៨៨% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន ៤៥ ៨៩៥ហ.ត។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើង (៩១,១៧%) ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របី (៨,៨៣%) ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ក្រៅពីដំណាំស្រូវ ដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម ក៏មានការកើនឡើងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ មកដល់ពេលនេះ កសិករបាននិងកំពុងប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះល្បឿននៃការប្រមូលផលស្រូវស្រាលដើមរដូវវស្សាទទួលបាន ៨៩,៦៧% នៃផ្ទៃដីអនុវត្ត ៦៣២ ៥០៨ហ.ត។ ចំណុចគួរកត់សម្គាល់មួយទៀតគឺ ការចូលរួមជាមួយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជនដើម្បីរិះរកដំណោះស្រាយតាមគ្រប់រូបភាពអំពីមូលបញ្ហាដែលបណ្តាលឱ្យតម្លៃស្រូវធ្លាក់ចុះក្នុងតំណាក់កាលដែលកសិករកំពុងប្រមូលផលស្រូវស្រាលដើមរដូវនេះ រួមទាំងការលើកទិសដៅអនុវត្តបន្តដើម្បីកាត់បន្ថយបញ្ហាប្រឈមខាងលើនេះ។ ដោយឡែក មន្រ្តីជំនាញរដ្ឋបាលព្រៃឈើបានបន្តកិច្ចសហការជាមួយគណៈកម្មការជាតិ និងអាជ្ញាធរថ្នាក់ក្រោមជាតិ ចុះប្រតិបត្តិការត្រួតពិនិត្យ ទប់ស្កាត់ និងបង្រ្កាបបទល្មើសព្រៃឈើនៅតាមអធិការដ្ឋានរដ្ឋបាលព្រៃឈើទាំង៤ តាមស្មារតីនៃសេចក្តីសម្រេច លេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចាត់អង្គភាពជំនាញដែលជាសេនាធិការក្នុងការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀត ដូចជាបទល្មើសជលផល ចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈព្រមទាំងជំរុញការងារផ្សព្វផ្សាយកសិកម្មយ៉ាងសកម្មផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែតុលា ឆ្នាំ២០១៦នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវ

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ មានលម្អិតដូចខាងក្រោម៖



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

○ ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣ ០០១ ០៩៥ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ២៦៥ ១០២ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧៣៥ ៩៨៣ហ.ត តិចជាងឆ្នាំមុនចំនួន ៥៥២ ៤៣០ហ.ត គិតក្នុងរយៈពេលដូចគ្នា

○ ផ្ទៃដីសាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុនចំនួន ២០ ៤៥៤ហ.ត

○ ផ្ទៃដីសន្ទូង និងពង្រោះសម្រេចបានចំនួន ២ ៥៩៧ ៤១២ហ.ត ស្មើនឹង ១០៤,៨៨% នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុនចំនួន ៤៥ ៩៩៨ហ.ត និងស្រូវតាមប្រភេទរួមមាន៖

-ស្រូវស្រាលចំនួន ៦៣២ ៥០៨ហ.ត លើសឆ្នាំមុនចំនួន ៤៧ ៧០៤ហ.ត

-ស្រូវកណ្តាលចំនួន ១ ៣២៤ ៩៦១ហ.ត លើសឆ្នាំមុនចំនួន ១៥ ៥៤៦ហ.ត

-ស្រូវធ្ងន់ចំនួន ៥៧១ ០៤៧ហ.ត លើសឆ្នាំមុនចំនួន ៤៥៦ហ.ត

-ស្រូវចម្ការចំនួន ២៨ ១៦៧ហ.ត តិចជាងឆ្នាំមុនចំនួន ១១ ៧៧៨ហ.ត

-ស្រូវឡើងទឹកចំនួន ៤០ ៧២៩ហ.ត តិចជាងឆ្នាំមុនចំនួន ៦ ០៣០ហ.ត។

○ គ្រោះជំនន់ទឹកភ្លៀងប៉ះពាល់លើផ្ទៃដីសរុបចំនួន ១៩ ០២៦ហ.ត ក្នុងនោះខូចខាតសន្ទូង-ពង្រោះសរុបចំនួន ៣ ៦២៥ហ.ត ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី-ខេត្ត | ប៉ះពាល់ (ហ.ត) | | ខូចខាត (ហ.ត) | |
|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| ១ | កំពង់ស្ពឺ | - | ៦ ៣៦៩ | - | ៤៣៩ |
| ២ | ស្វាយរៀង | - | ៣ ៤៧៧ | - | ៨៧២ |
| ៣ | កំពង់ឆ្នាំង | - | ៨១៣ | - | - |
| ៤ | ព្រៃវែង | - | ៥ ៧០២ | - | ២ ២៥៤ |
| ៥ | ត្បូងឃ្មុំ | - | ៣៤០ | - | ៦០ |
| ៦ | តាកែវ | - | ២ ៣២៥ | - | - |
| សរុប | | - | ១៩ ០២៦ | - | ៣ ៦២៥ |

○ ការងារប្រមូលផលស្រូវស្រាលដើមរដូវរហូតមកដល់ពេលនេះ សម្រេចបានចំនួន ៣១៤ ១៧៣ហ.ត លើផ្ទៃដីអនុវត្តស្រូវស្រាលសរុប ៦៣២ ៥០៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ១ ២២៧ ៥៦៦តោន លើសឆ្នាំមុន ៤៣៩ ៤៧៣តោន។ ទិន្នផលគិតជាមធ្យម ៣,៩០៧តោន/ហ.ត លើសឆ្នាំមុន ៤៥១គ.ក្រ/ហ.ត។

## ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៩១៨ ៣៦៦ហ.ត លើសឆ្នាំមុនចំនួន ៥៤ ០៧៥ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៨៣៤ ១៣០ហ.ត ស្មើនឹង ១៣៥,៣៨% នៃផែនការ ៦១៦ ១២៣ហ.ត លើសឆ្នាំមុនចំនួន ៩០ ១១៤ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨៤ ២៣៦ហ.ត ស្មើនឹង៦១,៣៨% នៃផែនការ ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុនចំនួន ៣៦ ០៣៦ហ.ត។

## ១.៤ ការនាំចេញអង្ករ

ការនាំចេញអង្ករកម្ពុជារយៈពេល១០ខែដើមឆ្នាំ២០១៦នេះ មានបរិមាណសរុបចំនួន ៤២១ ៥២១តោន ដែលមានការកើនឡើងចំនួន ១៣ ៣៥២តោន (+៣,៣%) លើសបរិមាណនាំចេញរយៈពេល១០ខែដើមឆ្នាំ២០១៥ ដែលមានចំនួន ៤០៨ ១៦៩តោន។ ក្នុងនោះបរិមាណនាំចេញក្នុងខែតុលានេះមានចំនួន ៦០ ០១៦តោន ដែលមានការកើនឡើងចំនួន ២០ ៩៥២តោន (+៥៣,៦០%) ច្រើនជាងខែតុលា ឆ្នាំ២០១៥ ដែលនាំចេញបាន ៣៩ ០៦៤តោន និងបាននាំចេញ

ទៅកាន់ទិសដៅចំនួន ៦៣ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៨៩ ៩៤៦តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៦១ ១៧៣តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (៥៦ ១៥១តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ (២៦ ៨៩១តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (២១ ៩៩៤តោន) ប្រទេសបែលហ្សិកឈរលំដាប់ទី៦ (១៨ ៨២៥តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៧ (១៧ ៣៥៧តោន) ប្រទេសឆេកឈរលំដាប់ទី៨ (១៦ ៤៧១តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៩ (១៤ ៩៥៨តោន) និងប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី១០ (១១ ៥៦៧តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៨១ក្រុមហ៊ុន (កើន ០៤ក្រុមហ៊ុនក្នុងខែតុលា)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៥៨៣ | ៧៧៦ | ៥៧៦ | ៥០០ |
| | **សរុប I** | **៥៨៣** | **៧៧៦** | **៥៧៦** | **៥០០** |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១២ ២៣៣ | ១៥ ៦៥៨ | ១២ ២៤៩ | ១៣ ២៦១ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់បេីលីមីធីត (រតនគិរី) | ៧៩ | ២ ៤៩៨ | ៦១ | ៧៤ |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ៩៩០ | ២ ១០១ | ៩២៣ | ៩១៣ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ១១០ | ៥ ៦៣៣ | ៣ ២២២ | ៣ ១៩៦ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣ ៩៩៧ | ៨ ៦៦១ | ២ ៤៨៣ | ២ ៦៣៥ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសសស់ (ស្នួល) | ១ ៧៤៥ | ៤ ៣៦៥ | ១ ៤២៥ | ១ ២៧៨ |
| ៧ | ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ១ ៨៨២ | ៣ ៣៩០ | ៧៦៩ | ៨២៨ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ១ ៤៦៥ | ១ ៥៥២ |
| ៩ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៤ ០៣៥ | ៥ ៧៣១ | ៣ ៣៧២ | ៣ ៨១៧ |
| | **សរុប II** | **៣១ ៣៩៨** | **៥៣ ៩៦១** | **២៥ ៩៦៩** | **២៧ ៥៥៤** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤ ៨៦៩ | ១៩៥ ៤៨១ | ៥ ៥៤៧ | ៥ ៣០៧ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៨៦ ២៥១ | ១៥១ ៩២១ | ៦៨ ៦៧០ | ៦៦ ៣៧៥ |
| | **សរុប III** | **៩១ ១២០** | **៣៤៧ ៤០២** | **៧៤ ២១៧** | **៧១ ៦៨២** |
| | **សរុប I+II+III** | **១២៣ ១០១** | **៤០២ ១៣៩** | **១០០ ៧៦២** | **៩៩ ៧៣៦** |

- គួរកត់សម្គាល់ថា សម្រាប់ខែតុលា ឆ្នាំ២០១៦នេះ តម្លៃកៅស៊ូជាមធ្យមក្នុងរង្វង់ ១ ២៤៧ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមសិក្ខាសាលាស្តីពីយន្តការដោះស្រាយបញ្ហាតម្លៃកៅស៊ូចុះថោក នៅប្រទេសស្រីលង្កា
- បានចូលរួមសិក្ខាសាលាស្តីពីការការពារនិងគ្រប់គ្រងចម្រុះចំពោះជំងឺ និងកត្តាចង្រៃនៃដំណាំកសិកម្មសម្រាប់ប្រទេសអាស៊ាន នៅសាធារណរដ្ឋប្រជាមានិតចិន
- បានចុះត្រួតពិនិត្យការថែទាំចម្ការកៅស៊ូ និងស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ក្លូន IRAA01-IRAA09

- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ៣៥ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរបស់រោងចក្រកែច្នៃកៅស៊ូ

- ចូលរួមធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១១៥ជាមួយ IRA ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងក្នុងតំបន់សម្រាប់កិច្ចសន្យាកៅស៊ូ TSR

- បានរៀបចំធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៤៧ដើម្បីវាយតម្លៃសមត្ថភាពមន្ទីរពិសោធន៍មូលដ្ឋាន

- បានស្រង់ទិន្នន័យជ័រគ្រប់ចម្ការពិសោធន៍ និងឧតុនិយម Sap flow និងFlux Tower

- ដាក់ជីបំប៉នកូនកៅស៊ូឆ្នាំ២០១៣-២០១៥ និងរៀបចំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៦-២០១៧ និងដាំជួសកូនកៅស៊ូដែលដាំឆ្នាំ២០១៥ និងឆ្នាំ២០១៦

- បានចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូ CSR និងទទួលស្គាល់ជាផ្លូវការមន្ទីរពិសោធន៍យថាប្រភេទរបស់ក្រុមហ៊ុនស៊ីធី រ៉ាប់ប៊ើរ ខូអិលធីឌី នៅខេត្តត្បូងឃ្មុំ

- វិភាគ តាមមេត្រូឡាក់ DRC តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍

- ដឹកនាំការសរសេរសារណារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម

- បណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាលាជាតិកសិកម្មព្រែកលៀប។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមប្រជុំស្តីអំពីការរៀបចំអនុស្សរណៈនៃការយោគយល់គ្នានិងផែនការសកម្មភាពរវាងភាគីកម្ពុជា និងភាគីថៃ

- បានប្រជុំដើម្បីរកវិធានការទប់ទល់នឹងការធ្លាក់ចុះថ្លៃផលិតផលកសិកម្ម ជាពិសេសតម្លៃស្រូវក្នុងរដូវច្រូតកាត់

- បានបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នឹងឯកសារពង្រាងស្នើសុំចុះកិច្ចសន្យា គំរូកិច្ចសន្យា សារាចរណែនាំ និងរៀបចំការបង្កើតគណៈកម្មាធិការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានរៀបចំផែនការសកម្មភាពគម្រោងលើកទី៣ ដាក់ជូនសហភាពអឺរ៉ុប (EU) ពាក់ព័ន្ធផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានចូលរួមប្រជុំជាមួយក្រុមហ៊ុនជប៉ុន JAPAN FARM PRODUCTS (Cambodia) Co., Ltd និង SARAYA (Cambodia) Co., Ltd ស្តីពីការគ្រោងធ្វើគម្រោងទាក់ទងវិស័យកសិកម្មក្រោមជំនួយរបស់ ទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិ JICA។

## ៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងកំពុងរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** មន្ត្រីជំនាញបានបន្តចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព មានការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយដៃគូពាក់ព័ន្ធ។
- **ការងារឡជីវឧស្ម័ន៖** បន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននិងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន ១១៨ឡ និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន ២៥០ឡ។

- **ចំណីសត្វ៖**បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។
- **ការងារដំណាំចំណីសត្វ៖** បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសូនដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

## ៤.២ ការងារបសុព្យាបាល

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖

រាជធានី-ខេត្តចំនួន ១២បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៣ ៤៥៨លើកនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលនិងបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៥០,៧គីឡូក្រាម ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនជ្រូករស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងរាលដាលនៃជំងឺជ្រូកត្រចៀកខៀវមកពីខេត្តជិតខាង។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តាខេត្ត-រាជធានី។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៤៨កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។
- **ស្ថិតិសត្តឃាតដ្ឋានដែលទទួលបានការអនុញ្ញាតនៅទូទាំងប្រទេសសរុបចំនួន ១៤៨កន្លែង ហើយចំនួនសត្វដែលបានពិឃាតក្នុងសត្តឃាតដ្ឋានទាំងនោះ ដូចមានតារាងខាងក្រោម៖**

| ល.រ | ឈ្មោះរាជធានី-ខេត្ត | ចំនួនសត្តឃាតដ្ឋាន | | ចំនួនសត្វពិឃាត | | | |
|---|---|---|---|---|---|---|---|
| | | សត្តឃាតដ្ឋានស្របច្បាប់ | ពិឃាតប្រមូលផ្តុំ/ពិឃាតតាមផ្ទះ | គោ (ក្បាល) | ក្របី (ក្បាល) | ជ្រូក (ក្បាល) | មាន់ (ក្បាល) |
| ១ | ភ្នំពេញ | ១២ | | ១៨៧ | | ១ ៨៦២ | |
| ២ | កណ្តាល | ២៣ | | ៤១៧ | | ៩ ៩៥៥ | ៧៤ ៨០០ |
| ៣ | កំពង់ស្ពឺ | ១១ | | ៦៧៥ | | ២ ៩៨៤ | |
| ៤ | ព្រៃវែង | ១២ | | ៣៣៨ | ២ | ៣ ៣៥០ | |
| ៥ | ស្វាយរៀង | ៨ | | ២០៣ | ៨ | ១ ៦៧៩ | |
| ៦ | កំពង់ឆ្នាំង | ១០ | | | | | |
| ៧ | ពោធិ៍សាត់ | ៦ | | | | | |
| ៨ | បាត់ដំបង | ១៤ | | ៤៦១ | | ២ ៧៣៦ | ១ ៦២៤ |
| ៩ | បន្ទាយមានជ័យ | ១១ | | ១ ៤៦០ | ៨ | ៦ ១៨១ | |
| ១០ | សៀមរាប | ៧ | | | | | |
| ១១ | កំពង់ធំ | ៦ | | ៥ ៧៣៤ | ៧២៥ | ៣៣ ១៣៨ | |
| ១២ | ព្រះសីហនុ | ៣ | | | | | |
| ១៣ | កែប | ១ | | | | | |
| ១៤ | កំពត | ៥ | | ២៥១ | | ២ ០៦៧ | ១ ៤០០ |
| ១៥ | កោះកុង | ៣ | | | | | |
| ១៦ | ក្រចេះ | ៥ | | ៤៦៤ | ៨ | ២ ៧១៣ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៧ | ស្ទឹងត្រែង | ១ | | | | | |
| ១៨ | រតនគិរី | ៣ | | | | | |
| ១៩ | មណ្ឌលគិរី | ២ | | | | | |
| ២០ | ប៉ៃលិន | ៣ | | | | | |
| ២១ | ឧត្តរមានជ័យ | ១ | | | | | |
| ២២ | តាកែវ | ១ | ១៨ | | | | |
| ២៣ | កំពង់ចាម | | ១០ | | | | |
| ២៤ | ត្បូងឃ្មុំ | | ៧ | | | | |
| ២៥ | ព្រះវិហារ | 0 | 6 | | | | |
| សរុប | | ១៤៨ | ៤១ | ១០ ១៩០ | ៧៥១ | ៦៦ ៦៦៥ | ៧៧ ៨២៤ |

• **ការងារនីតិកម្មនិងវិវាទ៖** បន្ទាប់ពីច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ត្រូវបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្រសួងបានរៀបចំបោះពុម្ពនិងធ្វើសិក្ខាសាលាផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយ និងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់តាមអាទិភាព។

**៤.៣ ការងារស្រាវជ្រាវ៖**

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ក្នុងខែតុលានេះ អង្គភាពជំនាញបានពិនិត្យវត្ថុវិភាគសរុបចំនួន ៤ ៤៣០ករណី។

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំតាម៉ៅមានគោសរុបចំនួន ១១១ក្បាល ក្នុងនោះគោបាចំនួន ១ក្បាល គោប្រាម៉ាន់កាត់ចំនួន ៦ក្បាល គោជំទង់ចំនួន ៣៨ក្បាល គោបៅដោះចំនួន ២៧ក្បាល គោកំជែងសែនចំនួន ៣៩ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុបចំនួន ១៩៨ក្បាល ក្នុងនោះជ្រូកបាចំនួន ៦ក្បាល ជ្រូកមេចំនួន ៦១ក្បាល កូនជ្រូកចំនួន ៣០ក្បាល កូនជ្រូកលក់ចំនួន ៨០ក្បាល និងជ្រូកបម្រុងចំនួន ១៥ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បានចាត់ថ្នាក់គម្របព្រៃឈើឆ្នាំ២០១៦ សម្រេចបាន ២៥%

- បានរៀបចំផែនការសកម្មភាព សម្រាប់ការវាយតម្លៃកម្រិតជឿជាក់ផែនទីបម្រែបម្រួលធនធានគម្របព្រៃឈើឆ្នាំ២០០៦-២០១៤ ជាមួយអ្នកជំនាញការ FAO

- បានចុះកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើចំនួន ០៣ មានផ្ទៃដីសរុបចំនួន ១ ៨០២ហ.ត នៅស្រុករវៀង ខេត្តព្រះវិហារ

- បានពិនិត្យ និងកែសម្រួលផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ០២ មានផ្ទៃដីសរុបចំនួន ១ ៤៧០ហ.ត នៅភូមិក្រឡាពាស និងភូមិក្រោម ឃុំព្រះរំកិល ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើចំនួន ០៣ ដែលមានឈើហ៊ុបមូលចំនួន ៥ ៣៧៨ម៣ កូនឈើចំនួន ៤៧ ៦៧៦ដើម អុសចម្រុះចំនួន ៧៧ ៨៧៣ស្ទែរ និងឫស្សីចំនួន ៦៤២តោន។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋចំនួន ០៣គ្រួសារ ដែលទទួលរងការបំផ្លាញដំណាំពីសត្វដំរីព្រៃ និងបានកត់ត្រាការខូចខាតចេកអស់ ៣៩គុម្ព នៅខេត្តព្រះសីហនុ។ ដំរីស្រុកចុះប្រេងចំនួន ០១ក្បាលបានជាន់ម្ចាស់ស្លាប់នៅឃុំស្រែអំពូម ខេត្តមណ្ឌលគិរី និងចុះដំឡើងម៉ាស៊ីនថតស្វ័យប្រវត្តនិងភ្លើងញាក់ដើម្បីការពារដំរីចូលស៊ីដំណាំ

- បានចុះផ្សព្វផ្សាយស្តីពីសារៈសំខាន់និងការជួញដូរសត្វព្រៃចំនួន ០២លើកនៅក្នុងខេត្តក្រចេះ ដែលមានអ្នកចូលរួមសរុបចំនួន ៥៩នាក់។

### ៥.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែតុលា ឆ្នាំ២០១៦នេះ ការងារនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាគឺ៖ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន ៤៤ក្បាល សត្វកើតថ្មីចំនួន ១០ក្បាល ព្យាបាលសត្វព្រៃរបួស និងឈឺចំនួន ២៣ក្បាល ដោះលែងទៅព្រៃធម្មជាតិវិញចំនួន ១៦០ក្បាល ជួសជុលផ្លូវមានប្រវែង ២៩៣ម៉ែត្រ កាប់ឆ្ការអនាម័យព្រៃមចំនួន ១,៨៥ហ.ត កំពុងសាងសង់ទ្រុងបង្កាត់ពូជក្រពើភ្នំទំហំ ២៦ម គុណ ១៥ម។ សត្វព្រៃសរុបចំនួន ១ ២៨២ក្បាល (បក្សី ៥០ប្រភេទ ថនិកសត្វ ៤៥ប្រភេទ និងល្មូន ១៣ប្រភេទ)។

### ៥.៤ ការងារដាំដើមឈើ

- បានដាំកូនឈើជាចម្ការនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួនបីកន្លែងសម្រេចបានលទ្ធផលលើផ្ទៃដីទំហំ ៣៥០ហ.ត

- បានថែទាំចម្ការឈើពីឆ្នាំទី១ដល់ ឆ្នាំទី៥ មានផ្ទៃដីសរុបទំហំ ២ ១៩៣ហ.ត ស្ថិតនៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទូទាំងប្រទេស

- បានបណ្តុះកូនឈើគ្រប់ប្រភេទបានចំនួន ៩ ៥២៦ដើម
- បានចែកកូនឈើជូនប្រជាពលរដ្ឋបានចំនួន ៨៤ ៧៦២ដើម។

### ៥.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេស (ក្រុមហ៊ុនចំនួន ០១ បានសុំបន្តសុពលភាព)

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលរានទេវតាទៅបរទេសចំនួន ០២ក្រុមហ៊ុន ដែលមានបរិមាណសរុប ១៨ម៣ និងជ័រទឹកចំនួន ៥០ តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ០១ក្រុមហ៊ុនប្រភេទឈើ MDF មានបរិមាណសរុប ៣៣ម៣ ។

### ៥.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែតុលាឆ្នាំ២០១៦នេះចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើសរុបចំនួន១ ៧៨៦ ២៨០ ៣៥៣រៀល និងចំណូលពីសេវាសាធារណៈចំនួន ៣៨៥ ៥៨៧ ១៣២រៀល និង ១៥ ១៥៧,៥២ដុល្លារអាមេរិក។

### ៥.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែតុលាឆ្នាំ២០១៦នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ១២៩ករណី ដោយបញ្ជូនទៅតុលាការចំនួន ៩៩ករណីនិងពិន័យអន្តរការណ៍ចំនួន ៣០ករណី

- ឃាត់ខ្លួនជនល្មើសនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ២៣ម៣ ឈើអារចំនួន ២៨៩ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៣០៦ក្បាល និង៧៦គ.ក្រ អនុផលព្រៃឈើ និងសម្ភារផ្សេងៗមួយចំនួនទៀត ដកហូតរណារយន្តបានចំនួន ១០គ្រឿង និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ១៦ករណី មានផ្ទៃដីព្រៃឈើដែលកាប់រានចំនួន ១០៣ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

## ៦ ផ្នែកផលផល

### ៦.១ អាជីវកម្មនេសាទ

៦.១.១ នេសាទទឹកសាប

- ដាយត្រី អនុវត្តបានចំនួន ៥៥០តោន សរុបរយៈពេល១០ខែបានចំនួន ១ ៦០០តោន ស្មើនឹង ១៣,៣៣% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ១ ៤៧៥តោន

- នេសាទគ្រួសារក្នុងដែននេសាទ អនុវត្តបានចំនួន ៣៨ ៦០០តោន សរុបរយៈពេល១០ខែបានចំនួន ២៤៤ ៦០០តោន ស្មើនឹង ៧១,១០% នៃផែនការ ៣៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៩ ០០០តោន

- នេសាទគ្រួសារតាមវាលស្រែ អនុវត្តបានចំនួន ២០ ៩០០តោន សរុបរយៈពេល១០ខែបានចំនួន ៩២ ៥០០តោន ស្មើនឹង ៦៤,២៤% នៃផែនការ ១៤៤ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១២ ៧៥៨តោន។

៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១១ ០០០តោន សរុបរយៈពេល១០ខែបានចំនួន ៩៦ ៤០០តោន ស្មើនឹង ៨៧,៦៤% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៦ ៩០០តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ១១ ៥០០តោន សរុបរយៈពេល១០ខែបានចំនួន ១៥៤ ៨៥០តោន ស្មើនឹង ៨៩,៦១% នៃផែនការ ១៧២ ៨០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៣០ ៧៥០តោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ៣០ ០០០ក្បាល សរុបរយៈពេល១០ខែបានចំនួន ២៦៧ ០០០ក្បាល ស្មើនឹង១០៦,៨០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៦១ ៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ អនុវត្តបានចំនួនប្រមាណ ២០ ០០០ ០០០កូន សរុបរយៈពេល១០ខែបានចំនួន ១៦៩ ០០០ ០០០កូន ស្មើនឹង ៩៣,៨៩% នៃផែនការ ១៨០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥កើនឡើងចំនួនប្រមាណ ៩ ០០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាប អនុវត្តបានចំនួន ៧ ០០០តោន សរុបរយៈពេល១០ខែបានចំនួន ៥៣ ៧០០តោន ស្មើនឹង ៦៥,៤៩% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៧ ២០០តោន ផលនេសាទសមុទ្រ អនុវត្តបានចំនួន ៩០០តោន សរុបរយៈពេល១០ខែបានចំនួន ៩ ២២៥តោន ស្មើនឹង១១៥,៣១% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ កើនឡើងចំនួន ៩២៥តោន

- ការផលិតទឹកត្រី អនុវត្តបានចំនួន ២ ៥០០ ០០០លីត្រ សរុបរយៈពេល១០ខែបានចំនួន ៤៧ ០០០ ០០០លីត្រ ស្មើនឹង ៩៤,០០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៥ ០០០ ០០០លីត្រ។

### ៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ៦០០តោន សរុបរយៈពេល១០ខែបានចំនួន ៧ ៤០០តោន ស្មើនឹង ៤៩,៣៣% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៤០០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ៤០០តោន សរុបរយៈពេល១០ខែបានចំនួន ៤ ១០០តោន ស្មើនឹង ៨២,០០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១០០តោន។

### ៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- សម្រាប់ខែតុលា ឆ្នាំ២០១៦នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ៣៦៦ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៨៥ករណី និងសមុទ្រចំនួន ៨១ករណី



ៃ

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ២៤២ ៦២៩ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៤ ៣២៧មាត់ បង្គោល/ចម្រឹងចំនួន ៩១ ១០២ដើម ឧបករណ៍ឆក់ត្រីចំនួន ១២គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ១៩ ៥២១គ.ក្រ

- ចាប់ពីដើមឆ្នាំ២០១៦នេះ បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ១៤៦វគ្គ ដោយមានអ្នកចូលរួមចំនួន ៥ ៧៩០នាក់ ក្នុងនោះស្ត្រីចំនួន ៩៣២នាក់។ ដោយឡែកក្នុងខែតុលា ឆ្នាំ២០១៦ នេះ អនុវត្តបាន ១៧វគ្គ ដោយមានអ្នកចូលរួមចំនួន ៤២៩នាក់

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យ និងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព និងចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសជលផលក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយគណៈបញ្ជាការឯកភាពរាជធានី-ខេត្ត។

### ៦.៦ ការប្រមូលចំណូល

- ចំណូលពីវិស័យជលផល សម្រាប់ខែតុលា ឆ្នាំ២០១៦ ចំនួន ២០៤ ២៥០ ២០០រៀល សរុបរយៈពេល១០ខែ បានចំនួន ១ ៧៨៩ ៩៣២ ៦៨០រៀល ស្មើនឹង ៥៩,៦៦% នៃផែនការ ៣ ០០០ ០០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ១ ២៩៤ ៧២៨ ២៩៥រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមទិវាស្បៀងអាហារពិភពលោកឆ្នាំ២០១៦ និងរៀបចំតាំងពិព័រណ៍លទ្ធផលស្រាវជ្រាវរបស់វិទ្យាស្ថាន ដែលប្រព្រឹត្តទៅនៅខេត្តស្វាយរៀង

- បានចូលរួមសិក្ខាសាលា ស្តីពីការអភិវឌ្ឍកសិកម្ម និងការដាំដំណាំពោតបារាំងនៅកម្ពុជា ដែលប្រព្រឹត្តទៅនៅខេត្តសៀមរាប

- បានចូលរួមសិក្ខាសាលា ស្តីពីដៃគូពាក់ព័ន្ធថ្នាក់ជាតិលើផែនទីគ្រោះគ្រវិទ្យាដំណាំស្រូវ

- បានជួបពិភាក្សាការងារជាមួយ Mr. Zhou Yunlong, Mr. Wang Zhi, Mrs. Duan Weixia, Mr. Ping Zhonglin, និង Mrs. Yang Pinli ស្តីពីការពិភាក្សាផ្លាស់ប្តូរយោបល់ និងសហប្រតិបត្តិការអំពីបញ្ហាកសិកម្មមួយចំនួន

- បានជួបពិភាក្សាការងារជាមួយ Mrs. Watanabe Ayako, Mr. Yoshiyuki Ishizaki, Mr. Neak Thon ស្តីពីការពិភាក្សាស្ថានភាពផលិតកម្មពូជ ដើម្បីរៀបចំគម្រោងបន្តជួយផលិតពូជនៅកម្ពុជា

- បានចុះជ្រើសរើសទីកន្លែងសម្រាប់ការសិក្សាវិធីសាស្ត្រ ច្រូតកាត់ នៅខេត្តតាកែវ

- បានចុះត្រួតពិនិត្យ និងបើកវគ្គបណ្តុះបណ្តាលដល់កសិករចំនួន១៨៥នាក់ នៅខេត្តព្រៃវែង ស្វាយរៀង កែប និងពោធិ៍សាត់។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៣ក្រុមហ៊ុន សរុបចំនួន ១៥២មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៦ក្រុមហ៊ុន ត្រូវជា២៤ករណី
- ចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មចំនួន ០១ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិជីកសិកម្មចំនួន ០៣ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០២ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជិកាចំនួន ១១ក្រុមហ៊ុន សរុបចំនួន ៦៤សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ និងខេត្តសៀមរាប សរុបចំនួន ១២០នាក់

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការជំរុញ ការនុវត្តលិខិតតុបករណ៍គតិយុត្តអាស៊ាន និងឯកសារពាក់ព័ន្ធថ្នាក់ជាតិ"។

### ៨.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលរបស់ក្រុមហ៊ុនដែលបានប្រកាសប្រតិវេទន៍អំពីការនាំចូល និងស្នើសុំចុះបញ្ជិកាឃ្លាំងសន្និធិជីកសិកម្ម និងថ្នាំកសិកម្មចំនួន ០២ក្រុមហ៊ុន។

## ៩ ផ្នែករដ្ឋបាល

- ក្នុងខែតុលា ឆ្នាំ២០១៦នេះ ទទួលលិខិតពីក្រសួង-ស្ថាប័ននានា បានចំនួន ៣០២ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៩១ច្បាប់ និងទទួលពីរាជធានី-ខេត្តចំនួន ១២៨ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៩១១ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥០ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ២៣ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការរៀបចំពិធីបុណ្យផ្សេងៗ និងការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួង

- បានរៀបចំនិងចាត់ចែងបញ្ជូនសារាចរណែនាំស្តីពី វិធានការជំរុញការស្តារឡើងវិញការខូចខាតដោយគ្រោះទឹកជំនន់ទឹកភ្លៀងរដូវវស្សា ឆ្នាំ២០១៦ ទៅស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួង។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៥៨៩នាក់ នារីចំនួន ១ ៣៩១នាក់ ស្មើនឹង ២១% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ៣ ៩៨៨នាក់ ក្នុងនោះនារីចំនួន ៨០៩នាក់ ស្មើនឹង ២០%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ២ ៦០១នាក់ ក្នុងនោះនារីចំនួន ៥៨២នាក់ ស្មើនឹង ២២%

- ចេញប្រកាសលុបឈ្មោះមន្ត្រីសុំលាឈប់ពីការងារចេញពីក្របខ័ណ្ឌមានចំនួន ០៨នាក់ ក្នុងនោះបោះបង់ការងារចំនួន ០៥នាក់ និងមរណភាពចំនួន ០៣នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន ៤៧នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន ០១នាក់

- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារចំនួន ០៨នាក់ ក្នុងនោះឈប់សម្រាកប្រចាំឆ្នាំចំនួន ០៥នាក់ និងសម្រាកលំហែមាតុភាពចំនួន ០៣នាក់

- បានធ្វើលិខិតផ្តល់នីត្យានុកូលភាពជូនមន្ត្រីកសិកម្មចំនួន ២២នាក់

- បានធ្វើផែនការក្របខ័ណ្ឌឆ្នាំ២០១៦-២០១៧ ទៅក្រសួងមុខងារសាធារណៈ។

## ១១ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលទៅក្រសួងពាណិជ្ជកម្ម អំពីការផ្តល់យោបល់លើសេចក្តីព្រាងឯកសារគោលគំនិត ស្តីពីការតភ្ជាប់អាស៊ាន-សហរដ្ឋអាមេរិក

- បានស្នើសុំសិទ្ធិប្រទានពីរាជរដ្ឋាភិបាលដើម្បីសុំចុះហត្ថលេខាលើពិធីសាររវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយអគ្គរដ្ឋបាលត្រួតពិនិត្យគុណភាព អធិការកិច្ច និងចត្តាឡីស័កនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការនាំអង្ករ និងចុងអង្ករទៅប្រទេសចិន

- បានសម្របសម្រួលចុះ MOU រវាងរដ្ឋបាលព្រៃឈើ និងវិទ្យាស្ថានជាតិធនធានជីវចម្រុះនៃសាធារណរដ្ឋកូរ៉េ ដើម្បីបន្តកិច្ចសហប្រតិបត្តិការលើធនធានជីវចម្រុះនិងព័ត៌មាន

- បានលើកសំណើទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសុំអ្នកជំនាញស្ម័គ្រចិត្តជនជាតិកូរ៉េ World Friend Korea: Advisors Program ១រូប តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ សម្រាប់នាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

- បានសម្របសម្រួលរាល់កិច្ចការទំនាក់ទំនងក្នុង និងក្រៅប្រទេសដើម្បីជូនថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទក្រសួងបានទៅចូលរួមបេសកកម្ម សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានានៅក្រៅប្រទេស រួមទាំងការទទួលជួបសវនាការរបស់ថ្នាក់ដឹកនាំជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍នានាផងដែរ។

## ១២ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១២.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៥-២០១៦ សរុបចំនួន ៦៦៤នាក់ (ស្ត្រី ២៣១នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៥០៥នាក់(ស្ត្រី ១៨៣នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ១៥៩នាក់(ស្ត្រី ៤៨នាក់)

- បានរៀបចំសិក្ខាសាលាស្តីពី ការកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រសម្រាប់ការសិក្សាឆ្នាំថ្មី ព្រមទាំងបានធ្វើការពិសោធន៍ស្រូវជប៉ុនទទួលបានលទ្ធផលគួរឱ្យចាប់អារម្មណ៍ និងបានស្នើសុំទៅប្រទេសសិង្ហបុរីដើម្បីធ្វើការពិនិត្យ

- បានទៅទស្សនកិច្ចនៅសាកលវិទ្យាល័យជាតិឆាយីនៃកោះតៃវ៉ាន់ សម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគត

- បានចូលរួមសិក្ខាសាលាស្តីពីការជំរុញការអនុវត្តន៍លិខិតុបករណ៍គតិយុត្តអាស៊ាន និងឯកសារពាក់ព័ន្ធ

- បានចូលរួមប្រជុំរៀបចំផែនការសកម្មភាព នៃកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់នឹងការប្រែប្រួលអាកាសធាតុ។

### ១២.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៥-២០១៦ សរុបមានចំនួន ៩០៨នាក់(ស្ត្រី ៣៧០នាក់) រួមមានៈ និស្សិតអាហារូបករណ៍សរុប ៨៥៩នាក់ (ស្ត្រី ៣៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្មចំនួន ៤៥៥នាក់ (ស្ត្រី ១៧៨នាក់) និងថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសកសិកម្មចំនួន ១២៥នាក់(ស្ត្រី ៥១នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃចំនួន ៤៩នាក់ (ស្ត្រី ១៦នាក់) ថ្នាក់បរិញ្ញាបត្រចំនួន ៣៨នាក់(ស្ត្រី ១៥នាក់) និងថ្នាក់បរិញ្ញាបត្ររងចំនួន ១១នាក់ (ស្ត្រី ១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយអង្គការពេទ្យសត្វគ្មានព្រំដែនដើម្បីរៀបចំមន្ទីរពិសោធន៍សត្វ និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍

- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន ព្រមទាំងជាមួយទីភ្នាក់ងារ KOICA និង JICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យ ០២រូប ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិត នៅប្រទេសកូរ៉េ និងជប៉ុន

- បានទទួលជួបតំណាង JICA ពិភាក្សាពីការរៀបចំគម្រោងកសិកម្មសរីរាង្គ គម្រោងស្រាវជ្រាវ គម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម ព្រមទាំងបានសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលស្តីពីកាកសំណល់រឹង និងរាវនៅទីសត្តឃាតដ្ឋានដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វចំនួន ៤៥នាក់។

### ១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតសិក្សានាឆ្នាំសិក្សាថ្មី២០១៦-២០១៧នេះ មាននិស្សិតសរុបចំនួន ៣១០០នាក់ ចែកចេញជា១០មហាវិទ្យាល័យគឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងថ្នាក់ក្រោយឧត្តម

ដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានប្រារព្ធពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី២០១៦-២០១៧ កាលពីថ្ងៃ១៨ ខែតុលា និងបានចូលរួមវគ្គសិក្សាអប់រំផ្លូវចិត្តរយៈពេល៣ថ្ងៃ ដោយសហការជាមួយអង្គការសម្ព័ន្ធយុវជនអន្តរជាតិកូរ៉េ

- បានចូលរួមប្រជុំជាមួយបណ្តាសាកលវិទ្យាល័យនៅកម្ពុជា និងសាកលវិទ្យាល័យប្រទេសជប៉ុនលើកទី១នៅ CJCC ស្តីអំពីកិច្ចសហប្រតិបត្តិការលើផ្នែកអប់រំស្រាវជ្រាវ ការពង្រឹងធនធានសាស្ត្រាចារ្យ និងសេវាកម្មគាំទ្រនិស្សិតកម្ពុជា និងជប៉ុន

- បានជួបគណៈប្រតិភូតំណាងក្រសួងអប់រំជប៉ុន មកទស្សនកិច្ចពិនិត្យមើលសមិទ្ធផលនានានៃកិច្ចសហប្រតិបត្តិការវាងសាលា និងសាកលវិទ្យាល័យណាហ្គូយ៉ា ដែលមានដូចជាបន្ទប់ VIDEO Conference បន្ទប់ពិសោធន៍ស្ថានីយចិញ្ចឹមគោទឹកដោះ និងគោសាច់ ជាដើម

- បានបញ្ជូនមន្ត្រីសាស្ត្រាចារ្យ និងនិស្សិតទៅចូលរួមវគ្គបណ្តុះបណ្តាល និងកម្មវិធីផ្លាស់ប្តូរនិស្សិតផ្សេងៗ នៅសាកលវិទ្យាល័យដៃគូនៅបរទេសបានមួយចំនួន និងបានទទួលនិស្សិត និងបុគ្គលិកសិក្សាពីសាកលវិទ្យាល័យដៃគូមកធ្វើកម្មសិក្សានៅសាលាផងដែរ

- ក្រោមគម្រោង ASPIRE សាលា បានបើកវគ្គបណ្តុះបណ្តាលរយៈពេល៣ខែ ស្តីពី ទីប្រឹក្សាផ្សព្វផ្សាយកសិកម្មជូនដល់មន្ត្រីកសិកម្ម គ្រប់ខេត្តក្រុង ចំនួន៣០នាក់។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងរួមផ្សំនឹងទឹកធ្លាក់មកពីតំបន់ភ្នំ និងការធ្លាយទំនប់ស្វាយ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានធ្វើឱ្យប៉ះពាល់លើដំណាំស្រូវនៅតាមបណ្តាខេត្តមួយចំនួនដូចជា បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល ព្រៃវែង ស្វាយរៀង សៀមរាប តាកែវ ត្បូងឃ្មុំ និងរាជធានីភ្នំពេញ។ រីឯការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយដោយសម្រេចបាន ១០៤,៨៨% លើសឆ្នាំមុន ៩៥ ៨៩៨ហ.ត (ស្មើនឹង ៥,៤៩%) បើប្រៀបធៀបរយៈពេលដូចគ្នា។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រោកសស្រាំរបស់បងប្អូនកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវប្រាំង ដោយគិតគូរទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ព្រមទាំងជំរុញការជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ។ ក្នុងកាលៈទេសៈដែលកសិករកំពុងប្រមូលផលស្រូវស្រាលដើមរដូវវស្សានេះក៏មានការបន្ទាបតម្លៃស្រូវនៅលើទីផ្សារ ដែលធ្វើឱ្យប៉ះពាល់ទៅលើចំណូលរបស់កសិករផងដែរ។ ករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការណែនាំទៅដល់អង្គភាពជំនាញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តដោយត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញពាក់ព័ន្ធដើម្បីជួយរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាព។ ជាពិសេស កិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមទាំងអស់នេះ ដែលអាចកើតឡើងជាយថាហេតុនៅពេលខាងមុខព្រមទាំងការអនុវត្តតាមស្មារតីនៃលិខិតលេខ៩៤២ សជណ.កស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារផ្នែកស្រូវអង្ករនៃវេទិកាრាជរដ្ឋាភិបាលផ្នែកឯកជន។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ ជាមួយគ្នានេះ ក្រសួងក៏បានរៀបចំជាគណៈកម្មការ និងក្រុមការងារតាមការចាំបាច់ដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើត

ឡើងនៅតាមអនុវិស័យនីមួយៗ។ ជាពិសេស បន្តយកចិត្តទុកដាក់ក្នុងការផ្ទេរមុខងាររបស់ខ័ណ្ឌរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលទៅថ្នាក់ក្រោមជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការតាមផ្នែកសំខាន់ៗផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការឆ្នាំ២០១៦នេះ។

## IV- **ទិសដៅអនុវត្តបន្ត**

### **១ ផ្នែកដាំដុះ** :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦-២០១៧

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាពសន្សំសំចៃ ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ ព្រមទាំងចូលរួមទប់ស្កាត់ការបញ្ចុះតម្លៃកសិផល ពិសេសតម្លៃស្រូវក្នុងពេលប្រមូលផលចុងរដូវនេះ

- ពិនិត្យឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវទាន់ពេលវេលា ចាត់ចែងជាបន្តក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋាន ព្រមទាំងកំពុងរៀបចំចាត់មន្ត្រីជំនាញ ដើម្បីត្រួតពិនិត្យអនាម័យនិងភូតគាមអនាម័យនៅតាមច្រកនាំចេញនាំចូលឱ្យបានសមស្របតាមវិធានបច្ចេកទេស និងនីតិវិធីដោយអនុលោមតាមស្មារតីនៃលិខិតលេខ ៩៤២ សជណ.កស ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចនិងផ្តល់ក្តីសង្ឃឹមអំពីតម្លៃកៅស៊ូនៅលើទីផ្សារដែលអាចនឹងឡើងថ្លៃវិញនៅពេលអនាគត។

### **២ ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ ក៏ដូចជាជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្ត

ធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣ ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាព រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

**៤ ផ្នែកជលផល**:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំ

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការរៀបចំអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលតាមគំរូថ្មីដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៩៥ សសរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥

- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា តាមស្មារតីនៃលិខិតលេខ១៣០៣ សជណ.សរ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ គោលការណ៍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទ ការសម្រួលភារកិច្ចក្នុងការបញ្ចូលខ័ណ្ឌរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រាជធានី-ខេត្ត ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ និងការផលិតសម្រាប់ឈានទៅរកការធ្វើសមាហរណកម្មពាណិជ្ជកម្មផលិតផលកសិកម្មក្នុងបរិបទនៃសាកលភាវូបនីយកម្ម៕

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**